## សំណួរ-ចម្លើយក្នុងការបំពេញព័ត៌មាន/ទិន្នន័យរបាយការណ៍ស្ថានភាពសហគ្រាស គ្រឹះស្ថាន និងការថែមម៉ោង

សូមស្វាគមន៍មកកាន់ ប្រព័ន្ធរបាយការណ៍ស្ថានភាពសហគ្រាស គ្រឹះស្ថានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាប្រព័ន្ធសម្រាប់រាយការណ៍ប្រចាំថ្ងៃអំពីស្ថានភាពទូទៅ និងការអនុវត្តលក្ខខណ្ឌទូទៅនៃការងារក្នុងសហគ្រាស គ្រឹះស្ថាន។

ជាដំបូង សូមលោកអ្នក ចូលទៅកាន់គេហទំព័រ https://ot.mlvt.gov.kh រួចចុចលើពាក្យ **ចូលប្រព័ន្ធ។** បន្ទាប់មកសូម លោកអ្នក បញ្ចូល **អ៊ីមែល** និង **លេខសម្ងាត់** នៃគណនីសហគ្រាស គ្រឹះស្ថាន របស់លោកអ្នកក្នុងប្រព័ន្ធ LACMS រួចចុចលើពាក្យ **ចូលប្រព័ន្ធ** នោះលោកអ្នកនឹងឃើញគេហទំព័រថ្មីមួយទៀត គឺ **ទម្រង់ធ្វើបច្ចុប្បន្នភាពប្រចាំថ្ងៃអំពីស្ថានភាពរបស់សហគ្រាស គ្រឹះស្ថាន។**

បន្ទាប់មកលោកអ្នកត្រូវបំពេញព័ត៌មានសំខាន់ៗ នៅផ្នែកទី១ នោះគឺ **ព័ត៌មានទូទៅរបស់សហគ្រាស គ្រឹះស្ថាន** ដែលក្នុងនោះមានកម្រងសំណួរចំនួន ១៥ ដែលលោកអ្នកត្រូវបំពេញ៖

**សំណួរទី១.** តើគិតត្រឹមថ្ងៃនេះ សហគ្រាស គ្រឹះស្ថានរបស់អ្នកកំពុងប្រើប្រាស់កម្មករនិយោជិតប៉ុន្មាននាក់?

សូម លោកអ្នក បំពេញចំនួនកម្មករនិយោជិតសរុប, កម្មករនិយោជិតស្រីសរុប, កម្មករនិយោជិតបរទេសសរុប និងកម្មករនិយោជិតបរទេសស្រីសរុប ដែលសហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក កំពុងប្រើប្រាស់គិតត្រឹមថ្ងៃដែល លោកអ្នកកំពុងធ្វើការរាយការណ៍។

**សំណួរទី២.** តើផលិតផលចម្បងនៃសហគ្រាស គ្រឹះស្ថានរបស់អ្នកជាផលិតផលអ្វី?

សូម លោកអ្នក វាយបញ្ចូលនូវប្រភេទនៃផលិតចម្បងដែលសហគ្រាស គ្រឹះស្ថាន លោកអ្នកកំពុងផលិត។ ឧទាហរណ៍៖ ខោខូវប៊ូយ អាវរងា ស្បែកជើង កាបូបស្ពាយ -ល-។

**សំណួរទី៣.** តើបច្ចុប្បន្នផលិតផលម៉ាកអ្វីខ្លះ ដែលសហគ្រាស គ្រឹះស្ថានរបស់អ្នកកំពុងផលិត?

ជាដំបូងសូមលោកអ្នកជ្រើសរើសផលិតផលម៉ាកណាមួយដែលសហគ្រាស គ្រឹះស្ថានរបស់អ្នកកំពុងផលិត រួចបំពេញចំនួនផលិតផលនោះ គិតជាភាគរយនៃផលិតផលម៉ាកដែលកំពុងផលិតសរុប។ លោកអ្នកអាចជ្រើសរើសផលិតផលម៉ាកបានច្រើនទៅតាមភាពជាក់ស្តែង។ ក្នុងករណីម៉ាកផលិតផលដែលលោកអ្នកកំពុងផលិត មិនមាននៅក្នុងបញ្ជីរបស់ប្រព័ន្ធ សូម លោកអ្នក ជ្រើសរើសពាក្យថា "Other"។

**សំណួរទី៤.** តើទីតាំងសហគ្រាស គ្រឹះស្ថានរបស់អ្នកសព្វថ្ងៃទិញ ឬជួល?

សូម លោកអ្នក ជ្រើសរើសចម្លើយ ទិញ ឬ ជួល យោងតាមភាពជាក់ស្តែង

**សំណួរទី៥.** តើអគារសហគ្រាស គ្រឹះស្ថានរបស់អ្នកសព្វថ្ងៃទិញ សាងសង់អគារខ្លួនឯង ឬជួល?

សូម លោកអ្នក ជ្រើសរើសចម្លើយ ទិញ ឬ ជួល យោងតាមភាពជាក់ស្តែង

**សំណួរទី៦.** តើក្នុងឆ្នាំ២០២៤ សហគ្រាស គ្រឹះស្ថានរបស់អ្នកមាននាំចេញផលិតផលទៅបរទេសដែរ ឬទេ?

សូម លោកអ្នក ជ្រើសរើសចម្លើយពាក់ព័ន្ធនឹងការនាំចេញផលិតផលទៅបរទេសរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក ក្នុងឆ្នាំ២០២៤ ដូចខាងក្រោម៖

- **បម្រើឱ្យការនាំចេញ (មានការនាំចេញ)** សំដៅដល់សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក បាននាំចេញទំនិញដោយផ្ទាល់ទៅបរទេស។ ករណីនេះ សូម លោកអ្នក ជ្រើសរើសប្រទេសដែលជាទីផ្សារនាំចេញរបស់សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក រួចបំពេញទំហំនៃការនាំចេញទៅប្រទេសនោះគិតជា ដុល្លារអាមេរិក និងគិតជាភាគរយ នៃចំនួនបាននាំចេញសរុបក្នុងឆ្នាំ២០២៤។ ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមានទីផ្សារនាំចេញទៅច្រើនប្រទេស សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។

- **ផ្គត់ផ្គង់ដល់សហគ្រាសដែលបម្រើឱ្យការនាំចេញ** សំដៅដល់ សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នកផលិតផលិតផលសម្រាប់ផ្គត់ផ្គង់ដល់សហគ្រាស គ្រឹះស្ថាន មួយផ្សេងទៀត ដែលជាអ្នកនាំចេញទៅបរទេស។
- **បម្រើទីផ្សារក្នុងស្រុក** សំដៅដល់សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក ផលិតផលិតផលសម្រាប់តែផ្គត់ផ្គង់ទីផ្សារក្នុងស្រុក មិនមានធ្វើការនាំចេញ ឬផ្គត់ផ្គង់ដល់សហគ្រាសដែលបម្រើឱ្យការនាំចេញ។

* **លោកអ្នក អាចជ្រើសរើសចម្លើយច្រើនជាងមួយ ទៅតាមស្ថានភាពជាក់ស្តែងនៃសហគ្រាស គ្រឹះស្ថានរបស់លោកអ្នក។**

**សំណួរទី៧.** តើក្នុងខែមុន សហគ្រាស គ្រឹះស្ថានរបស់អ្នកបាននាំចេញផលិតផលទៅបរទេសដែរ ឬទេ?

សូម លោកអ្នក ជ្រើសរើសចម្លើយពាក់ព័ន្ធនឹងការនាំចេញផលិតផលទៅបរទេសរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក ក្នុងខែមុន ដូចខាងក្រោម៖

- **បម្រើឱ្យការនាំចេញ (មានការនាំចេញ)** សំដៅដល់សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក បាននាំចេញទំនិញដោយផ្ទាល់ទៅបរទេស។ ករណីនេះ សូម លោកអ្នក ជ្រើសរើសប្រទេសដែលជាទីផ្សារនាំចេញរបស់សហគ្រាស គ្រឹះស្ថានរបស់លោកអ្នក រួចបំពេញទំហំនៃការនាំចេញទៅប្រទេសនោះគិតជា ដុល្លារអាមេរិក និងគិតជាភាគរយ នៃចំនួនបាននាំចេញសរុប។ ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមានទីផ្សារនាំចេញទៅច្រើនប្រទេស សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។
- **ផ្គត់ផ្គង់ដល់សហគ្រាសដែលបម្រើឱ្យការនាំចេញ** សំដៅដល់ សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក ផលិតផលិតផលសម្រាប់ផ្គត់ផ្គង់ដល់សហគ្រាស គ្រឹះស្ថាន មួយផ្សេងទៀត ដែលជាអ្នកនាំចេញទៅបរទេស។
- **បម្រើទីផ្សារក្នុងស្រុក** សំដៅដល់សហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក ផលិតផលិតផលសម្រាប់តែផ្គត់ផ្គង់ទីផ្សារក្នុងស្រុក មិនមានធ្វើការនាំចេញ ឬផ្គត់ផ្គង់ដល់សហគ្រាសដែលបម្រើឱ្យការនាំចេញ។

* **លោកអ្នក អាចជ្រើសរើសចម្លើយច្រើនជាងមួយ ទៅតាមស្ថានភាពជាក់ស្តែងនៃសហគ្រាស គ្រឹះស្ថានរបស់លោកអ្នក។**

**សំណួរទី៨.** តើសហគ្រាស គ្រឹះស្ថានរបស់អ្នកមានការរំពឹងទុកអំពីការនាំចេញក្នុងរយៈពេលមួយត្រីមាសបន្ទាប់យ៉ាងដូចម្តេច?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការរំពឹងទុកនៃការនាំចេញក្នុងត្រីមាសបន្ទាប់ ដូចខាងក្រោម៖

- **កើនឡើង** ករណីកើនឡើង សូមបញ្ចូលចំនួនជាភាគរយដែលរំពឹងថានឹងកើនឡើងនៃការនាំចេញ ឬ
- **ថយចុះ** ករណីថយចុះ សូមបញ្ចូលចំនួនជាភាគរយដែលរំពឹងថានឹងថយចុះនៃការនាំចេញ ឬ
- **រក្សានៅដដែល**

**សំណួរទី៩.** តើក្នុងឆ្នាំ២០២៤ សហគ្រាស គ្រឹះស្ថានរបស់អ្នកនាំចូលវត្ថុធាតុដើមពីប្រទេសណា?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការនាំចូលវត្ថុធាតុដើមរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក ដូចខាងក្រោម៖

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មាននាំចូលវត្ថុធាតុដើមពីបរទេសក្នុងឆ្នាំ២០២៤ សូមជ្រើសរើសចម្លើយថា "**មាន**" រួចសូមជ្រើសរើស ប្រទេសនាំចូល ព្រមជាមួយនឹងការបំពេញទំហំនៃការនាំចូល (គិតជាដុល្លាអាមេរិក) និងបំពេញទំហំនៃការនាំចូល (គិតជាភាគរយ) នៃចំនួននៃការនាំចូលវត្ថុធាតុដើមសរុបរបស់សហគ្រាស គ្រឹះស្ថាន ។

* ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមាននាំចូលវត្ថុធាតុដើមពីច្រើនប្រទេស សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មិនមាននាំចូលវត្ថុធាតុដើមពីបរទេសក្នុងឆ្នាំ២០២៤ សូមជ្រើសរើសចម្លើយថា "**គ្មាន**"។

**សំណួរទី១០.** តើក្នុងខែមុន សហគ្រាស គ្រឹះស្ថានរបស់អ្នកនាំចូលវត្ថុធាតុដើមពីប្រទេសណា?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការនាំចូលវត្ថុធាតុដើមរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក ដូចខាងក្រោម៖

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មាននាំចូលវត្ថុធាតុដើមពីបរទេសក្នុងខែមុន សូមជ្រើសរើសចម្លើយថា "**មាន**" រួចសូមជ្រើសរើស ប្រទេសនាំចូល ព្រមជាមួយនឹងការបំពេញទំហំនៃការនាំចូល (គិតជាដុល្លាអាមេរិក) និងបំពេញទំហំនៃការនាំចូល (គិតជាភាគរយ) នៃចំនួននៃការនាំចូលវត្ថុធាតុដើមសរុបរបស់សហគ្រាស គ្រឹះស្ថាន ។

* ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមាននាំចូលវត្ថុធាតុដើមពីច្រើនប្រទេស សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មិនមាននាំចូលវត្ថុធាតុដើមពីបរទេសក្នុងខែមុន សូមជ្រើសរើសចម្លើយថា "**គ្មាន**"។

**សំណួរទី១១.** តើសហគ្រាស គ្រឹះស្ថានរបស់អ្នកមានការរំពឹងទុកអំពីការនាំចូលវត្ថុធាតុដើមក្នុងរយៈពេលមួយត្រីមាសបន្ទាប់យ៉ាងដូចម្ដេច?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការរំពឹងទុកនៃការនាំចូលវត្ថុធាតុដើមក្នុងត្រីមាសបន្ទាប់ ដូចខាងក្រោម៖

- **កើនឡើង** ករណីកើនឡើង សូមបញ្ចូលចំនួនជាភាគរយដែលរំពឹងថានឹងកើនឡើងនៃការនាំចូលវត្ថុធាតុដើម ឬ
- **ថយចុះ** ករណីថយចុះសូមបញ្ចូលចំនួនជាភាគរយដែលរំពឹងថានឹងថយចុះនៃការនាំចូលវត្ថុធាតុដើម ឬ
- **រក្សានៅដដែល**

**សំណួរទី១២.** តើការបញ្ជាទិញដែលសហគ្រាស គ្រឹះស្ថានរបស់អ្នកកំពុងមានបច្ចុប្បន្នចំនួនប៉ុន្មាន និងផុតកំណត់នៅពេលណា?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការបញ្ជាទិញរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក នាពេលបច្ចុប្បន្ន ដូចខាងក្រោម៖

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក កំពុងមានការបញ្ជាទិញ សូមជ្រើសរើសចម្លើយថា "**មាន**" រួចបំពេញ **ចំនួនបញ្ជាទិញបច្ចុប្បន្នសរុប** និងបំពេញ**ទំហំនៃការបញ្ជាទិញទី១ គិតជាដុល្លារអាមេរិក** និង**កាលបរិច្ឆេទផុតកំណត់**។

* ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមានការបញ្ជាទិញច្រើន សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មិនមានការបញ្ជាទិញនោះ ទេ សូមជ្រើសរើសចម្លើយថា "**មិនមាន**"។

**សំណួរទី១៣.** តើការបញ្ជាទិញដែលសហគ្រាស គ្រឹះស្ថានរបស់អ្នកកំពុងមានបច្ចុប្បន្ន ត្រូវបានលុបចោលដែរឬទេ?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការលុបចោលនូវការបញ្ជាទិញរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក នាពេលបច្ចុប្បន្ន ដូចខាងក្រោម៖

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក បច្ចុប្បន្នមានការលុបចោលនូវការបញ្ជាទិញ សូមជ្រើសរើសចម្លើយថា "**មាន**" រួចបំពេញ **ចំនួននៃការលុបចោលនូវការបញ្ជាទិញបច្ចុប្បន្នសរុប, ទំហំនៃការលុបចោលនោះគិតជាដុល្លារអាមេរិក** និង**គិតជាភាគរយនៃការលុបចោលនូវការបញ្ជាទិញសរុបរបស់សហគ្រាស គ្រឹះស្ថាន។**

* ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមានការលុបចោលការបញ្ជាទិញច្រើន សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មិនមានការលុបចោលនូវការបញ្ជាទិញនោះទេ សូមជ្រើសរើសចម្លើយថា "**មិនមាន**"។

**សំណួរទី១៤.** តើសហគ្រាស គ្រឹះស្ថានរបស់អ្នកបានទទួលការបញ្ជាទិញថ្មីដែរឬទេ?

សូម លោកអ្នក ជ្រើសរើសចម្លើយអំពីការបញ្ជាទិញថ្មីរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក ដូចខាងក្រោម៖

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក ទទួលបានការបញ្ជាទិញថ្មី សូមជ្រើសរើសចម្លើយថា "**មាន**" រួចបំពេញ **ចំនួនបញ្ជាទិញថ្មីសរុប** និងបំពេញ**ទំហំនៃការបញ្ជាទិញទី១ គិតជាដុល្លារអាមេរិក** និង**កាលបរិច្ឆេទផុតកំណត់។**

* ករណីសហគ្រាស គ្រឹះស្ថានរបស់អ្នកមានការបញ្ជាទិញច្រើន សូមចុចលើពាក្យ **បន្ថែម** ដើម្បីបញ្ចូលព័ត៌មានបន្ថែម។

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មិនមានការបញ្ជាទិញថ្មីនោះទេ សូមជ្រើសរើសចម្លើយថា "**មិនមាន**"។

**សំណួរទី១៥.** តើការដឹកទំនិញចេញ/ការនាំចេញមានការពន្យាពេលដែរឬទេ?

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មានការពន្យាពេលក្នុងការដឹកទំនិញចេញឬនាំចេញ សូមជ្រើសរើសចម្លើយថា "**មាន**" រួចបំពេញ**ចំនួនថ្ងៃនៃការពន្យាពេល** និងជ្រើសរើស**ថាតើអ្នកណាជាអ្នកចំណាយលើថ្លៃស្តុកទំនិញនោះ៖**

- ☞ **អ្នកផលិត** ឬ
- ☞ **អ្នកបញ្ជាទិញ** ឬ
- ☞ **តាមការព្រមព្រៀងគ្នារវាងអ្នកផលិត និងអ្នកបញ្ជាទិញ** ករណីការចំណាយថ្លៃស្តុកទំនិញតាមការព្រមព្រៀងគ្នារវាងអ្នកផលិត និងអ្នកបញ្ជាទិញ។ សូមបញ្ជាក់ភាគរយដែលអ្នកផលិតត្រូវចំណាយ ដោយបញ្ចូលចំនួននៅចំណុច**អ្នកផលិត** និងសូមបញ្ជាក់ភាគរយដែលអ្នកបញ្ជាទិញត្រូវចំណាយ ដោយបញ្ចូល**ចំនួននៅចំណុចអ្នកបញ្ជាទិញ**។

ករណីសហគ្រាស គ្រឹះស្ថាន លោកអ្នក មិនមានការពន្យាពេលនៃការដឹកទំនិញចេញ/នាំចេញនោះទេ សូមជ្រើសរើសចម្លើយថា "**មិនមាន**"។

បន្ទាប់ពីបំពេញព័ត៌មាននៅផ្នែកទី១ចប់ សូម លោកអ្នក ចុចលើពាក្យ **បន្ត** ដើម្បីបំពេញព័ត៌មានសំខាន់ៗនៅផ្នែកទី២ នោះគឺ **ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តលក្ខខណ្ឌទូទៅនៃការងារ** ដែលក្នុងផ្នែកនេះ ដែរមានកម្រងសំណួរ**ចំនួន៨** ដែលលោកអ្នកត្រូវបំពេញ៖

**សំណួរទី១.** តើសហគ្រាស គ្រឹះស្ថានរបស់អ្នកបើកប្រាក់ឈ្នួលលើកទី១ នៅថ្ងៃណា?

- ➢ សូម លោកអ្នក ជ្រើសរើស **កាលបរិច្ឆេទបើកប្រាក់លើកទី១ របស់សហគ្រាស គ្រឹះស្ថាន**

**សំណួរទី២.** តើការបើកប្រាក់ឈ្នួលលើកទី១ នេះមានការយឺតយ៉ាវឬទេក្នុងខែនេះ?

ករណីសហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក មានការយឺតយ៉ាវ សូមជ្រើសរើសចម្លើយ "យឺត" រួចបំពេញចំនួនថ្ងៃនៃការបើកប្រាក់ឈ្នួលលើកទី១ ដែលយឺតនោះ។

ករណីសហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក មិនមានការយឺតយ៉ាវសូមជ្រើសរើសចម្លើយ "មិនយឺត"។

**សំណួរទី៣.** តើសហគ្រាស គ្រឹះស្ថានរបស់អ្នកបើកប្រាក់ឈ្នួលលើកទី២ នៅថ្ងៃណា?

- សូម លោកអ្នក ជ្រើសរើស **កាលបរិច្ឆេទបើកប្រាក់លើកទី២ របស់សហគ្រាស គ្រឹះស្ថាន។**

**សំណួរទី៤.** តើការបើកប្រាក់ឈ្នួលលើកទី២ នេះមានការយឺតយ៉ាវឬទេក្នុងខែនេះ?

ករណីសហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក មានការយឺតយ៉ាវសូមជ្រើសរើសចម្លើយ "យឺត" រួចបំពេញចំនួនថ្ងៃនៃការបើកប្រាក់ឈ្នួលលើកទី២ ដែលយឺតនោះ។

ករណីសហគ្រាស គ្រឹះស្ថានរបស់ លោកអ្នក មិនមានការយឺតយ៉ាវសូមជ្រើសរើសចម្លើយ "មិនយឺត"។

**សំណួរទី៥.** តើក្នុងថ្ងៃនេះសហគ្រាស គ្រឹះស្ថានរបស់អ្នកមានកម្មករនិយោជិតថែមម៉ោងសរុបប៉ុន្មាននាក់?

ករណីសហគ្រាស គ្រឹះស្ថានរបស់លោកអ្នកមានការធ្វើការបន្ថែមម៉ោង សូមជ្រើសរើសចម្លើយ "មាន" រួចបំពេញចំនួនកម្មករនិយោជិតសរុបដែលកំពុងធ្វើការបន្ថែមម៉ោងនោះ។

ករណីសហគ្រាស គ្រឹះស្ថានរបស់លោកអ្នកពុំមានការធ្វើការបន្ថែមម៉ោងទេ សូមជ្រើសរើសចម្លើយ "មិនមាន"។

**សំណួរទី៦.** តើមានការកាត់បន្ថយម៉ោងធ្វើការរបស់កម្មករនិយោជិតញឹកញាប់ដែរឬទេ?

សូម លោកអ្នកជ្រើសរើសចម្លើយអំពីការកាត់បន្ថយម៉ោងធ្វើការរបស់កម្មករនិយោជិត **"មាន"** ឬ **"មិនមាន"** ទៅតាមស្ថានភាពជាក់ស្តែងរបស់សហគ្រាស គ្រឹះស្ថាន លោកអ្នក។

**សំណួរទី៧.** តើក្នុងថ្ងៃនេះសហគ្រាស គ្រឹះស្ថានរបស់អ្នកមានព្យួរកិច្ចសន្យាការងារដែរឬទេ?

ករណីសហគ្រាស គ្រឹះស្ថានរបស់លោកអ្នកកំពុងមានព្យួរកិច្ចសន្យាការងារ សូមជ្រើសរើសចម្លើយ "មាន" រួចបំពេញចំនួនកម្មករនិយោជិតសរុបដែលត្រូវបានព្យួរកិច្ចសន្យាការងារនោះ។

ករណីសហគ្រាស គ្រឹះស្ថានរបស់លោកអ្នកពុំមានការព្យួរកិច្ចសន្យាការងារនោះទេ សូមជ្រើសរើសចម្លើយ "មិនមាន"។

**សំណួរទី៨.** តើក្នុងថ្ងៃនេះ សហគ្រាស គ្រឹះស្ថាន របស់អ្នកមានបញ្ឈប់កម្មករនិយោជិតដែរឬទេ?

ករណីសហគ្រាស គ្រឹះស្ថានរបស់លោកអ្នកមានការបញ្ឈប់កម្មករនិយោជិត សូមជ្រើសរើសចម្លើយ "មាន" រួចបំពេញចំនួនកម្មករនិយោជិតសរុបដែលត្រូវបានបញ្ឈប់ពីការងារនោះ។

ករណីសហគ្រាស គ្រឹះស្ថានរបស់លោកអ្នកពុំមានការបញ្ឈប់កម្មករនិយោជិតនោះទេ សូមជ្រើសរើសចម្លើយ "មិនមាន"។

☞ បន្ទាប់ពីបំពេញព័ត៌មាននៅផ្នែកទី២នេះចប់សព្វគ្រប់ សូមចុចលើពាក្យ ***រក្សាទុក*** ដើម្បីបញ្ជូនរបាយការណ៍នៃការរាយការណ៍ប្រចាំថ្ងៃអំពីស្ថានភាពទូទៅ និងការអនុវត្តលក្ខខណ្ឌទូទៅនៃការងារ ក្នុងសហគ្រាស គ្រឹះស្ថាន របស់លោកអ្នក

☞ បន្ទាប់ពីចុចលើពាក្យ ***រក្សាទុក*** លោកអ្នកនឹងទទួលបានការបញ្ជាក់ថា *លោកអ្នកបានធ្វើបច្ចុប្បន្នភាពស្ថានភាពសហគ្រាស គ្រឹះស្ថាន សម្រាប់ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥ រួចរាល់ និង ជោគជ័យ*